# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2013, 14:37
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើសុំអង្គជំនុំជម្រះសាលាដំបូង មិនផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយលើកមុន ទាក់ទងនឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSESWEIG
Forest O'NEILL-GREENBERG

**ផ្ញើជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

អនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") សហមេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះស្នើសុំអង្គជំនុំជម្រះសាលាដំបូង សម្រេចមិនផ្តល់ឲ្យសាក្សី ស៊ុន អាឡាត ពិច ឈឹម លាវ ឡាម ឬ ("អ្នកបើករថយន្តក្នុងវីដេអូ E186.R[1] នូវសំណៅនៃកំណត់ហេតុស្តាប់ចម្លើយលើកមុនរបស់ពួកគេនៅមុនការផ្តល់ការសក្ខីកម្មឡើយ៖

## I. ប្រតិបត្តិនីតិវិធី

១. នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាតាមរយៈអនុស្សរណៈអន្តរការិយាល័យបានស្នើអង្គជំនុំជម្រះសាលាដំបូងថា សាក្សីនិមួយៗដែលត្រូវកោះហៅឲ្យផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ត្រូវបានតែផ្តល់ជាមុននូវសំណៅនៃកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ពួកគេដើម្បី "រំលឹកដល់ការចងចាំរបស់ពួកគេ"[2]។ មេធាវីការពារ នួន ជា បានជំទាស់ទាំងផ្ទាល់មាត់[3] និងជាលាយលក្ខណ៍អក្សរ[4]។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញពីគោលបំណងរបស់ខ្លួន ដើម្បីទទួលយកសំណើនោះ[5] ហើយនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់របៀបលំអិតសម្រាប់នីតិវិធីនោះ[6]។

២. ក្នុងអំឡុងពេលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបន្តដាក់វិធានទាក់ទងនឹងការប្រើប្រាស់ឯកសារ និងវិធីសាស្ត្រនៃការពិនិត្យឯកសារ ។ វិធានបែបនេះបានបង្កើតការហាមឃាត់

---

[1] ឯកសារ E-292 សារអេឡិចត្រូនិកពី Susan Lam បញ្ជូនមកភាគី ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ។

[2] ឯកសារ **E-142** "សំណើអនុលោមតាមវិធាន៣៥ សុំការស៊ើបសួរទាក់ទងនឹងភាពមិនស្របគ្នានៅក្នុងខ្សែរអាត់សម្លេង និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស" ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ("សំណើទាក់ទងនឹងភាពមិនស្របគ្នានៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី") នៅកថាខណ្ឌ២២ ។

[3] ឯកសារ **E-1/16.1** "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ នៅទំព័រ 30:15-31:9 ។

[4] សំណើទាក់ទងនឹងភាពមិនស្របគ្នានៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅកថាខណ្ឌ២២-២៤ ។

[5] ឯកសារ **E-141** អនុស្សរណៈពី Susan Lam បញ្ជូនមកភាគី ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ នៅទំព័រ៤ ។

[6] ឯកសារ **E-141/1** អនុស្សរណៈពី Susan Lam ទៅ Wendy Lobwein ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ទូទៅលើការដាក់សំណួរនាំមុខ[7]។ សូមកត់សម្គាល់ថា អង្គជំនុំជម្រះនេះក៏បានយល់ឃើញថា ភាគីត្រូវបានអនុញ្ញាតឱ្យដកស្រង់ពីកំណត់ហេតុលើកមុនរបស់សាក្សី និងស្វែងរកការបញ្ជាក់ពីភាពពិតនៃខ្លឹមសាររបស់កំណត់ហេតុស្តាប់ចម្លើយនេះ ដោយមិនចាំបាច់ទាញការសន្និដ្ឋានពីសក្ខីកម្មនោះ តាមរយៈការសួរសំនួរបើកឡើយ[8]។

៣. ក្នុងអំឡុងសប្តាហ៍ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី អ៊ុង ឆាត និង លីម សាត ហើយនៅពេលនោះមានតែសាក្សីពីរនាក់ប៉ុណ្ណោះ ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងទួលពោធិ៍ជ្រៃ។ ក្នុងអំឡុងពេលនៃការសួរដេញដោលរបស់សហព្រះរាជអាជ្ញាលើសាក្សី អ៊ុង ឆាត មេធាវីការពារក្តីបានជំទាស់ទៅនឹងការប្រើប្រាស់កំណត់ហេតុជាក់លាក់មួយចំនួនដោយសហព្រះរាជអាជ្ញា:

> ខ្ញុំដឹងពីការអនុវត្តការអានឮៗកំណត់ស្តាប់ចម្លើយសាក្សីរបស់ កសចស ប៉ុន្តែនៅពេលនេះយើងបានឈានមកដល់ចំណុចមួយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដែលខ្ញុំយល់ឃើញថា ជាការចាំបាច់ត្រូវសួរសំនួរបើក។ វានឹងមិនធ្វើឱ្យអង្គជំនុំជម្រះនេះភ្ញាក់ផ្អើលទេ ដែលថា វាមានភស្តុតាងតិចតួចទៅលើអ្វីដែលបានកើតឡើងពិតប្រាកដនោះ ហើយដូច្នេះ ភស្តុតាងជាសក្តានុពលរបស់សាក្សីរូបនេះ អាចមានសារៈសំខាន់ខ្លាំងណាស់។ ដូច្នេះខ្ញុំគិតថា យើងបានឈានដល់ចំណុចមួយដែលសហការីរបស់ខ្ញុំនៅជ្រុងម្ខាងទៀត ត្រូវចោទសួរៈ លោកសាក្សីថាតើមានអ្វីកើតឡើង ហើយមិនត្រូវឱ្យគាត់អានកំណត់ហេតុនោះទេ-បញ្ហាជាក់លាក់ដែលគាត់បាននិយាយនៅ កសចស[9] ។

៤. ចៅក្រម Cartwright ផ្តល់ការសម្រេចរបស់អង្គជំនុំជម្រះដូចខាងក្រោម:

> អង្គជំនុំជម្រះសូមសង្កត់បញ្ជាក់ថា វិធានជាមូលដ្ឋានដូចដែលបានសង្ខេបដោយសហព្រះរាជអាជ្ញា នៅតែមានសុពលភាពដដែល ហើយថាការសម្រេចនេះមិនអាចប្រែប្រួលទេ។ ប៉ុន្តែអង្គជំនុំជម្រះឃើញពីការបារម្ភដែលលើកឡើងដោយក្រុមមេធាវីការពារក្តី នួន ជា ហើយថានេះ

---

[7] ឧទាហរណ៍សូមមើលឯកសារ **E-1/9.1** "ប្រតិចារិតសវនាការ" ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ នៅទំព័រ: 4:10-13 ។

[8] ឧទាហរណ៍សូមមើលឯកសារ **E-1/186.1** "ប្រតិចារិតសវនាការ" ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ នៅទំព័រ: 7:15-11:1

[9] ឯកសារ **E-1/186.1** "ប្រតិចារិតសវនាការ" ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ នៅទំព័រ: 7:16-25 ។

ជាពេលវេលាសមស្របបំផុតដែលត្រូវសួរសាក្សីនេះ ហើយអង្គជំនុំជម្រះអញ្ជើញសហព្រះរាជអាជ្ញាសួរសំណួរបើកច្រើនថែមទៀតចាប់ពីចំណុចនេះតទៅ[10]។

៥. ភ្លាមៗបន្ទាប់ពីការបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី អ៊ុង ឆាត និងលីម សាត អង្គជំនុំជម្រះបានបញ្ចេញបញ្ជីឈ្មោះសាក្សីចុងក្រោយរបស់ខ្លួន ដែលត្រូវកោះហៅឲ្យផ្តល់សាក្ខីនៅក្នុងករណី ០០២/០១[11]។ បន្ទាប់មកអង្គជំនុំជម្រះផ្តល់ឲ្យភាគីនូវឱកាសចុងក្រោយ ដើម្បីដាក់សួរបន្ថែមចំពោះសាក្សីទាក់ទងនឹង "បញ្ហាថ្មីពិតប្រាកដ"[12]។ ទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីស្វែងរកឲ្យកោះហៅសាក្សីបន្ថែម ទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលសន្មតថាបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ។ មេធាវីការពារក្តីលើកអំណះអំណាងថា សក្ខីកម្មរបស់សាក្សី អ៊ុង ឆាត និង លីម សាត "ងាកចេញយ៉ាងខ្លាំងពីភស្តុតាងដែលពួកគេបានផ្តល់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត [ហើយ] គាំទ្រខ្លាំងដល់ជំហររបស់មេធាវីការពារក្តី នួន ជា ដែលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអង្គហេតុដែលត្រូវបានគេសន្មតថា បានកើតឡើងនៅទួលពោធិ៍ជ្រៃ"[13]។ សហព្រះរាជអាជ្ញាយល់ស្របថា សាក្សីទាំងពីរនាក់បានផ្តល់សក្ខីកម្មមិនសមស្របជាមួយកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេនៅសហចៅក្រមស៊ើបអង្កេតឡើយ[14]។ ហេតុដូច្នេះ មេធាវីការពារក្តីស្នើសុំឱកាសសួរដេញដោលសាក្សីទាំងអស់ ដែលផ្អែកដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងទួលពោធិ៍ជ្រៃ ដើម្បីបង្កើតមូលដ្ឋានឲ្យបានច្បាស់នៅក្នុងតុលាការថា នួន ជា មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានា

---

[10] ឯកសារ **E-1/186.1** "ប្រតិចារិតសវនាការ" ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ នៅទំព័រ: 10:14-19 ។

[11] សារអេឡិចត្រូនិកពី Susan Lam បញ្ជូនមកភាគី ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ។

[12] ឯកសារ **E-288** អនុស្សរណៈពីប្រធានអង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ នៅកថាខណ្ឌ៣ ។

[13] ឯកសារ **E-291** "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ១ ។

[14] ឯកសារ **E-1/207.1** "ប្រតិចារិតសវនាការ" ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ នៅទំព័រ:70:15-71:14 ។

ដែលត្រូវបានសន្មតថា បានប្រព្រឹត្តនៅទីនោះ[15]។ សហព្រះរាជអាជ្ញា បានស្វែងរកឱ្យកោះហៅសាក្សីបីនាក់បន្ថែមទៀតទាក់ទងនឹងទួលពោធិ៍ជ្រៃ និងសាក្សីបីនាក់ ដែលទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជាចំពោះការសម្លាប់អតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ[16]។

៦. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានផ្តល់ការជូនដំណឹងជាមុនថា អង្គជំនុំជម្រះនឹងកោះហៅ (ឬខ្នះខ្នែងស្វែងរក ហើយជាបន្ទាប់កោះហៅ) ស៊ុន អាឡាត ពិច ឈឹម លាវ ឡាម និង"អ្នកបើកឡាននៅក្នុងវីដេអូ E186.R" ។ អង្គជំនុំជម្រះក៏បានចង្អុលបង្ហាញថា សាក្សីដទៃទៀតដែលស្នើឡើងដោយមេធាវីការពារក្តី អាចស្ថិតនៅក្រោមការពិចារណាជាសាក្សីបម្រុង[17]។

## II. អំណះអំណាង

៧. សម្រាប់កំណត់ត្រា មេធាវីការពារក្តីបញ្ជាក់ឡើងវិញពីការជំទាស់របស់ខ្លួនចំពោះការអនុវត្តនៃការផ្តល់ឱ្យសាក្សីនូវកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេ នៅមុនការចូលខ្លួនផ្តល់សក្ខីកម្ម ។ ដូចដែលមេធាវីការពារក្តីបានលើកអំណះអំណាងកាលពីលើកមុន ការអនុវត្តបែបនេះបង្កឱ្យផិតដាមជាប្រព័ន្ធដល់ភស្តុតាងដែលស្តាប់ដោយអង្គជំនុំជម្រះនេះ។ គោលបំណងមួយនៃគោលបំណងផ្សេងៗទៀតនៃការសួរដេញដោលសាក្សី គឺដើម្បីកំណត់ថា តើការចងចាំរបស់សាក្សីស្របគ្នានៅគ្រប់ពេលដែរ ឬយ៉ាងណា។ ព្រឹត្តិការណ៍បានកើតឡើងជាង៣០ឆ្នាំនៅមុនការស្តាប់ចម្លើយនេះ ហេតុដូច្នេះវាកើតចេញក្តីបារម្ភពិតប្រាកដអំពីគុណភាពនៃការចងចាំរបស់សាក្សី។ ការព្រួយបារម្ភទាំងនេះកាន់តែមានទម្ងន់ថែមទៀតដោយការដែលមេធាវីការពារក្តី

---

[15] ឯកសារ **E-291** "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ២៨ ។

[16] ឯកសារ **E-288/3** "ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាក្នុងការឆ្លើយតបចំពោះសំណើរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ សុំឱ្យផ្តល់ព័ត៌មាននៅមុនកិច្ចរៀបចំសវនាការ" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ៥ ។

[17] ឯកសារ E-292 សារអេឡិចត្រូនិកពី Susan Lam បញ្ជូនមកភាគី ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ។

ត្រូវបានបដិសេធទាំងស្រុងពីការស្តាប់ចម្លើយសាក្សីទាំងនោះ[18]ដែលផ្ទុយពីការអនុវត្តនៅតុលាការអនុវត្តច្បាប់ស៊ីវិល។ ការអនុញ្ញាតឱ្យសាក្សីអានកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេនៅមុនការផ្តល់សក្ខីកម្ម គឺប្រៀបដូចនឹងការជំនួសការចងចាំរបស់ពួកគេ [...] ច្រើនជាងការធ្វើឱ្យនឹកឃើញ ហើយវាធ្វើឱ្យបរាជ័យគោលបំណងនៃការសួរដេញដោល[19] ។

៨. អនុលោមតាមបទដ្ឋានអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍នានា ភាពមិនស្របគ្នានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីពីមួយពេលទៅមួយពេល គឺពាក់ព័ន្ធនឹងការវាយតម្លៃពីភាពអាចជឿជាក់បាន និងតម្លៃភស្តុតាងនេះ ខណៈដែលភាពមិនស្របគ្នានេះអាចមិនតម្រូវឱ្យបដិសេធចោលភស្តុតាងនេះ តែវាពាក់ព័ន្ធនឹងបញ្ហាថា តើភស្តុតាងមានទម្ងន់ដែរ ឬទេ ហើយបើសិនជាមានទម្ងន់ តើវាមានទម្ងន់ប៉ុន្មាន:

> វត្តមាននៃភាពមិនស្របគ្នានៅក្នុងភស្តុតាង មិនតម្រូវឱ្យអង្គជំនុំជម្រះដែលសមហេតុផលបដិសេធចោលភស្តុតាងនេះ ដោយសារភាពមិនអាចជឿជាក់បានរបស់វា។ ស្រដៀងគ្នានេះដែរ កត្តានានាដូចជាការកន្លងផុតទៅនៃពេលវេលារវាងព្រឹត្តិការណ៍ដែលបានកើតឡើង និងសក្ខីកម្មរបស់សាក្សី ឥទ្ធិពលពីសំណាក់តតីយជន ភាពមិនស្របគ្នាដោយអន្លើ ឬ អត្ថិភាពនៃលក្ខខណ្ឌលំបាកនៅពេលដែលព្រឹត្តិការណ៍នេះបានកើតឡើង ក៏មិនបានឱ្យអង្គជំនុំជម្រះមិនផ្អែកជាស្វ័យប្រវត្តិលើភស្តុតាងនេះដែរ។ តែអង្គជំនុំជម្រះត្រូវពិចារណាកត្តាបែបនេះដូចដែលអង្គជំនុំជម្រះវាយតម្លៃ និងថ្លឹងថ្លែងភស្តុតាងនេះដែរ[20]។

---

[18] ឯកសារ A-110/1 អនុស្សរណៈពីចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ERN 00157729-00157730 ។ French Code de Procédure Pénale, Art. 120 (‘Le juge d’instruction dirige les interrogatoires, confrontations et auditions. Le procureur de la République et les avocats des parties et du témoin assisté peuvent poser des questions ou présenter de brèves observations.’), Art. 82.1 (‘Les parties peuvent, au cours de l'information, saisir le juge d'instruction d'une demande écrite et motivée tendant à ce qu'il soit procédé à leur audition ou à leur interrogatoire, à l'audition d'un témoin, à une confrontation ou à un transport sur les lieux, à ce qu'il soit ordonné la production par l'une d'entre elles d'une pièce utile à l'information, ou à ce qu'il soit procédé à tous autres actes qui leur paraissent nécessaires à la manifestation de la vérité.’) ។

[19] សំណើទាក់ទងនឹងភាពមិនស្របគ្នានៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅកថាខណ្ឌ២៤ ។

[20] រឿងក្តីរដ្ឋអាជ្ញា តទល់ *Kupreskic* et al., IT-95-16, “សាលដីកា” ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ នៅកថាខណ្ឌ៣១។

ក្នុងករណីដែលសាក្សីត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលកំណត់ហេតុលើកមុនរបស់ខ្លួន នៅមុនការផ្តល់សក្ខីកម្ម ការវាយតម្លៃពេញលេញនៃភស្តុតាងនេះ មិនអាចធ្វើបានឡើយ ។ ជាការពិតការផ្តល់សក្ខីកម្មដោយផ្ទាល់អាចបញ្ជាក់លើកំណត់ហេតុស្តាប់ចម្លើយលើកមុន- ហើយហេតុដូច្នេះសក្ខីកម្មនេះហាក់ដូចជាមានភាពអាចជឿជាក់បានច្រើន ។ មិនមានអ្វីឱ្យភ្ញាក់ផ្អើលទេ ពុំមានតុលាការអន្តរជាតិណាផ្សេង ឬ យុត្តាធិការច្បាប់ស៊ីវិលផ្តល់ឱ្យសាក្សីពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយលើកមុនរបស់ខ្លួន នៅមុនការផ្តល់សក្ខីកម្មនោះទេ ។

៩. បើទោះបីអង្គជំនុំជម្រះជ្រើសរើសមិនយកចិត្តទុកដាក់ពីការព្រមានជាទូទៅនេះក៏ដោយ ក៏ការព្រមាននេះមានសារៈសំខាន់ទាក់ទងនឹងសាក្សី ស៊ុន អាឡាត ពិច ឈឹម លាវ ឡាម និង “អ្នកបើកឡាននៅវីដេអូ E186”។ ពេលនេះមិនមានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនេះនៃអង្គហេតុសំខាន់ដែលដាក់ នួន ជា ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទាក់ទងនឹងទួលពោធិ៍ជ្រៃឡើយ រួមទាំងភស្តុតាងណាមួយនៃការដឹងដោយផ្ទាល់របស់ នួន ជា នៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្លាប់អតីត ឬ មន្ត្រី ឬ ការសម្លាប់ដែលត្រូវបានគេនិយាយមានកើតឡើងនៅទួលពោធិ៍ជ្រៃ ហើយក៏មិនភស្តុតាងដែលអាចជឿជាក់បានពីចំនួន ឬសមាសភាពនៃជនរងគ្រោះ ឬភស្តុតាងបញ្ជាក់ថា តើពួកគេមកទួលពោធិ៍ជ្រៃដោយរបៀបណាដែរ[21]។ ដោយសារភាពដ៏កម្រនៃភស្តុតាងនេះ (ហើយជាលទ្ធផល សារសំខាន់នៃសាក្សីចំនួនតូចដែលផ្តល់សក្ខីកម្មនៅក្នុងករណី០០២) ដែលអង្គជំនុំជម្រះបានណែនាំសហព្រះរាជអាជ្ញាមិនឱ្យប្រើកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស ជាឧបករណ៍ចម្បងដើម្បីបង្កើតអង្គហេតុនានាទាក់ទងនឹង “ចំណុចប្រណិត” នៃការសួរដេញដោលសាក្សី ។

១០. នៅដំណាក់កាលនេះ ការសួរដេញដោលសាក្សីណាមួយទាក់ទងនឹងទួលពោធិ៍ជ្រៃ គឺជា“ចំណុចប្រណិត”។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញពីគោលបំណងរបស់ពួកគេដើម្បីសួរដេញដោលសាក្សីទាំងបួននាក់ដែលជ្រើសរើសអង្គជំនុំជម្រះ លើបញ្ហាអង្គហេតុដែលពាក់ព័ន្ធ

---

[21] ឯកសារ **E-291** “សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ទាក់ទងនឹងទួលពោធិ៍ជ្រៃ” ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ នៅទំព័រ៩-១៤ និង ៣២ ។

ដោយផ្ទាល់ទៅលើការចោទប្រកាន់នានាពាក់ព័ន្ធទួលពោធិ៍ជ្រៃ[22]។ សាក្សីថ្មីដែលកោះហៅដោយអង្គជំនុំជម្រះ ក៏ត្រូវបានស្វែងរកឲ្យកោះហៅដោយមេធាវីការពារ និងសហព្រះរាជអាជ្ញាដែរ ពីព្រោះសក្ខីកម្មរបស់សាក្សី អ៊ុំង ឆាត និង លឹម សាត មិនបានផ្ទុះបញ្ចាំងភស្តុតាងដែល (ត្រូវបានសន្មតថា) ពួកគេបានផ្តល់សហចៅក្រមស៊ើបអង្កេតឡើយ[23] ។ សារៈសំខាន់នៃកិច្ចដំណើរការនីតិវិធីនៅពេលនេះកាន់តែមានទំហំធំជាងនៅពេលអង្គជំនុំជម្រះណែនាំសហព្រះរាជអាជ្ញាមិនដាក់ភស្តុតាងពីកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុំង ឆាត នៅមុនពេលគាត់បានមើលសក្ខីកម្មរបស់គាត់ ។ ការបង្ហាញ ស៊ុន អាឡាត ពិច ឈឹម លាវ ឡាម និង អ្នកបើកឡាននៅវីដេអូ E186.R នូវកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេនៅមុនពួកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យអង្គភាព WESU ធ្វើកិច្ចនេះនៅក្រៅតុលាការ ដែលអង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើកិច្ចនេះនៅក្នុងតុលាការនោះ។

១១. បើតាមការពិចារណាទាំងនេះ សន្និទានភាពសម្រាប់ការអនុវត្តធម្មតា-ដែលអង្គជំនុំជម្រះបានបង្កើតនៅពេលចាប់ផ្តើមការជំនុំជម្រះនេះសម្រាប់គោលបំណងនៃការសម្របសម្រួលការផ្តល់សក្ខីកម្មរបស់សាក្សីទូទៅទាំងអស់-មិនអាចអនុវត្តចំពោះករណីនេះបានទេ ។ កាលពីលើកមុនអង្គជំនុំជម្រះនេះបានយល់ឃើញថា គោលបំណងនៃវិធាននេះ គឺ “ដើម្បីបញ្ចៀសការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃរបស់តុលាការ បើសិនសាក្សី […] ត្រូវការធ្វើឲ្យខ្លួនឯងធ្លឹកជាមួយកំណត់ហេតុលើកមុនរបស់ខ្លួន ឬដើម្បីបញ្ជាក់ថា ពួកគេបានថ្លែងពិតប្រាកដមែន”[24]។ ប៉ុន្តែការសន្សំពេលវេលាដែលត្រូវទទួលបានតាមរយៈការធានាថា សាក្សីទាំងបួននាក់ចងចាំថាបានផ្តល់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយលើកមុន គឺស្តួចស្តើង-ហើយប្រហែលជាមិនមានផង។ ផ្ទុយមកវិញ ហានិភ័យចំពោះសុចរិតភាពនៃកិច្ចដំណើរការនិតីវិធី គឺសំខាន់ណាស់។ តាមពិត“ប្រសិទ្ធិភាព”ពិតៗតែមួយគត់ អាចសម្រេចបាននៅពេលដែលការចងចាំរបស់សាក្សីងាកចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេដែលត្រូវបានសង្ខេបនៅក្នុង WRI ឬបង្ហាញ

---

[22] ឯកសារ **E-291** “ប្រតិចារិតសវនាការ” ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ នៅទំព័រ 60:25-61:9 ។

[23] សូមមើលកថាខណ្ឌ៥ ខាងលើ ។

[24] ឯកសារ **E-141/1** អនុស្សរណៈពី Susan Lam បញ្ជូនមក Wendy Lowein ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។

នៅក្នុង E186.R ។ នៅក្នុងករណីនោះ ការសួរដេញដោលភ្លាមៗលើការដឹងរបស់ពួកគេ ដែលមិនត្រូវបានផិតដាមដោយកំណត់ហេតុស្ដាប់ចម្លើយលើកមុនរបស់ពួកគេ គឺកាន់តែសំខាន់ថែមទៀត។

## III. សេចក្ដីសន្និដ្ឋាន និងការស្នើរកដំណោះស្រាយ

១២. នួន ជា ដាក់សំណើនេះនៅពេលនេះសម្រាប់មូលហេតុដូចគ្នា និងសាមញ្ញដែលគាត់ស្វែងរកឲ្យចូលខ្លួនរបស់សាក្សីទាំងអស់ ដែលផ្អែកដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងទួលពោធិ៍ជ្រៃ។ គាត់ចង់បានឱកាសពេញលេញ និងត្រឹមត្រូវដើម្បីតទល់ភស្តុតាងប្រឆាំងនឹងគាត់ដោយចំហនៅតុលាការ។ នៅក្រោមកាលៈទេសៈបែបនេះការអនុញ្ញាតឲ្យសាក្សីអាន ឬឃើញកំណត់ហេតុស្ដាប់ចម្លើយលើកមុនរបស់ពួកគេនៅមុនពួកគេផ្ដល់សក្ខីកម្ម អាចបង្កឲ្យការជំនុំជម្រះមានហានិភ័យ ។ ពុំមានមូលហេតុពិតប្រាកដ និងដែលអាចយល់បាន ហើយក៏ពុំមានផលប្រយោជន៍អ្វីដើម្បីបដិសេធសំណើនេះទេ ។

១៣. មេធាវីការពារក្ដីកត់សម្គាល់ថា ក្នុងអំឡុងពេលសួរដេញដោលសាក្សី នូ ម៉ុក នាសវនាការព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះនេះបានបង្ហាញដល់ភាគីថាអង្គភាព WESU បានផ្ដល់ដល់សាក្សីនូវរូបថតរបស់ Ben Kiernan សម្រាប់គោលបំណងបញ្ជាក់អត្តសញ្ញាណរបស់គាត់ ព្រមទាំងអត្ថបទបកប្រែជាភាសាខ្មែរនូវកំណត់ត្រារបស់សាស្ត្រាចារ្យ Ben Kiernan ដែលគាត់សម្ភាសន៍សាក្សីនេះ។ បើពិចារណាកំណត់ត្រាដែលមានលក្ខណៈមិនពិតរបស់ Ben Kiernan នេះគឺជាឧទាហរណ៍មួយនៃការអនុវត្តដែលអង្គជំនុំជម្រះគួរតែបញ្ចៀស ។ មេធាវីការពារក្ដីពិចារណាថា ការកំណត់អត្តសញ្ញាណរបស់សាក្សី នឹងតម្រូវឲ្យពិនិត្យសង្ខេបនៃរូបថតរបស់ Kiernan ហើយវាមិនតម្រូវឲ្យមានការកាន់កាប់កំណត់ត្រារបស់ Kiernan ទេ។

១៤. សម្រាប់មូលហេតុទាំងនេះ មេធាវីការពារក្ដីស្នើសុំដោយគោរពថា អង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា សាក្សី ស៊ុន អាឡែត ពិច ឈឹម លាវ ឡាម និង "អ្នកបើកឡាននៅវីដេអូ E186.R (ឬបុគ្គលណាផ្សេងទៀតដែលត្រូវកោះហៅជំនួសពួកគេ) នឹងមិនទទួលបាន ឬបង្ហាញព័ត៌មានណាមួយ រួមទាំងកំណត់ហេតុស្ដាប់ចម្លើយលើកមុនរបស់ពួកគេទាក់ទងនឹងអង្គហេតុនានានៅ

ទូលពោធិ៍ជ្រៃនៅក្នុងករណី០០២/០១ ឬផ្នែកណាមួយនៃវីដេអូ E186.R នៅមុនការផ្តល់សក្ខីកម្មរបស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះឡើយ ។

**សហមេធាវីការពារក្តីលោក នួន ជា**

| | |
|---|---|
| **សុន អរុណ** | Victor KOPPE |